# ទស្សនវិជ្ជាសីលធម៌របស់ព្រះពុទ្ធ

Buddha`s Ethical Philosophies

*ដោយៈ ឯកឧត្តមបណ្ឌិត* ***អ៊ុំ ប៉ុម***
*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្ដីផ្ដើម

*ទស្សនវិជ្ជាសីលធម៌របស់ព្រះពុទ្ធ គឺជាក្រុមទស្សនវិជ្ជាសីលធម៌ស្ថិតក្នុងផ្នែកមួយក្នុងចំណោមផ្នែកទាំងបួននៃទ្រឹស្ដីនយោបាយ[1] ដែលត្រូវបានបញ្ចូលជាផ្លូវការទៅក្នុងកម្មវិធីសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៃមុខវិជ្ជាវិទ្យាសាស្ត្រនយោបាយ។ ដោយឡែកបើគេនិយាយពីព្រះពុទ្ធវិញ អរិយបុគ្គលរូបនេះត្រូវបានសាកលលោកចាត់ទុកថាជាតួអង្គទស្សនវិទូដ៏ឆ្នើម (លោកវិទូ) មានលក្ខណៈសម្បត្តិពិសេសអាចប្រមើលមើលឃើញពិតដឹងពិតពីសកលលោកយើងនេះថែមទៀតផង។ ជាងនេះទៅទៀតក្នុងអត្ថិភាពជាមនុស្សព្រះអង្គបានរកឃើញតាមរយៈការត្រិះរិះពិចារណានូវទស្សនវិជ្ជាដ៏មានតម្លៃចំនួនបួនប្រកបដោយអត្ថន័យខ្លឹមសារអប់រំសីលធម៌ដ៏ជ្រាលជ្រៅអាចប្រើប្រាស់ជាមធ្យោបាយដើម្បីនាំមនុស្សលោកឆ្ពោះទៅរកសេចក្ដីសុខស្ងប់ ចាកផុតទុក្ខលំបាកគ្រប់បែបយ៉ាងព្រមទាំងកសាងបាននូវ មេត្រីភាពរវាងគ្នានឹងគ្នាដោយមិនប្រកាន់វណ្ណៈឬពណ៌សម្បុរអ្វីឡើយ។*

*តទៅនេះ គឺជាខ្លឹមសារជាក់ស្ដែងនៃទស្សនវិជ្ជាសីលធម៌ដែលព្រះពុទ្ធរកឃើញបន្ទាប់ពីបានសាកល្បងធ្វើទុក្ករកិរិយានិងស្វែងរកផ្លូវកណ្ដាលមួយ ដើម្បីការត្រាស់ដឹងជាព្រះពុទ្ធអស់រយៈពេលប្រាំមួយព្រះវស្សា។*

---

*១- ទ្រឹស្ដីនយោបាយបែបទស្សនវិជ្ជាសីលធម៌, ទ្រឹស្ដីនយោបាយបែបទេវកថា-សាសនា, ទ្រឹស្ដីនយោបាយបែបរដ្ឋប្បវេណីនិងទ្រឹស្ដីនយោបាយបែបសង្គម។*

## *១. សីលប្រាំឬបញ្ចសីលា*

*សីលប្រាំគឺជាសីលធម៌សង្គមដំបូងគេបង្អស់ដែលមនុស្សម្នាក់ៗគប្បីមានជាប្រចាំក្នុងចិត្តគំនិតរបស់ខ្លួនដើម្បីញ៉ាំងឲ្យការរស់នៅជារៀងរាល់ថ្ងៃបានល្អប្រសើរ។*

***ខ្លឹមសារនៃសីលប្រាំរួមមាន*** :

***១.១- កុំសម្លាប់ជីវិតអ្នកដទៃ (បាណាតិបាតា)*** : *ទាក់ទងជាសំខាន់ទៅនឹងសិទ្ធិរួសរានមានជីវិតរបស់មនុស្សម្នាក់ៗ។ ទោះបីស្ថិតក្នុងស្ថានភាពលំបាកលំបិនយ៉ាងណាក្តីក៏បុគ្គលម្នាក់ៗសុទ្ធតែមានបំណងចង់រស់រានមានជីវិតជាមនុស្សដូចៗគ្នា។*

***១.២- កុំកូតករកុហកអ្នកដទៃ (អទិន្នាទានា)*** : *បានន័យថាបុគ្គលម្នាក់ៗ ត្រូវនិយាយពិតនិយាយត្រង់មិននិយាយវៀចវេរក្រឡិចក្រឡុចបោកបញ្ឆោតអ្នកដទៃក្នុងទំនាក់ទំនងប្រចាំថ្ងៃរបស់ខ្លួន។*

***១.៣- មិនប្រព្រឹត្តខុសក្នុងកាម (កាមេសុមិច្ឆាចារា)*** : *ព្រះពុទ្ធបានអប់រំបុគ្គលម្នាក់ៗមិនឲ្យប្រព្រឹត្តរំលោភបំពានលួចសេពសន្ថវៈជាមួយកូនប្រពន្ធជាទីស្រឡាញ់របស់អ្នកដទៃ។ បើគេហ៊ានរំលោភបំពានប្រាកដណាស់ថា គេនឹងមិនបានសេចក្តីសុខឡើយ ព្រោះរូបគេបានប្រព្រឹត្តកន្ទង់ប្រពៃណីទៅបំផ្លាញសុកមង្គលរបស់គេធ្វើឲ្យគេឈឺចាប់ហើយអំពើសងសឹកគ្នាប្រាកដជាកើតមានដោយស្វ័យប្រវត្តិជៀសមិនផុតឡើយ។*

***១.៤- មិននិយាយបង្កាច់បង្ខូចអ្នកដទៃខុសការពិត (មុសាវាទា)*** : *ព្រះពុទ្ធបានហាមប្រាមមិនឲ្យបុគ្គលម្នាក់ៗ បៀតបៀនគ្នាតាមផ្លូវវាចា និយាយបង្កាច់បង្ខូចគ្នាខុសពីការពិត។*

***១.៥- មិនសេពគ្រឿងស្រវឹង (សុរាមេរ័យ)*** : *បើសេពគ្រឿងស្រវឹងច្បាស់ជាវង្វេងស្មារតី លែងដឹងខុសត្រូវអាក្រក់ល្អ ឈានទៅដល់ការបំពារបំពានដោយវាចាឬអំពើជាសកម្មភាពមិនគប្បីទាំងឡាយចំពោះគ្រួសារនិងចំពោះអ្នកដទៃ។ នេះមិនទាន់គិតដល់ការចុះទ្រុឌទ្រោមផ្នែកសុខភាពប្រាជ្ញាស្មារតីការទទួលខុសត្រូវនិងការបាត់បង់អាយុជីវិតផ្ទាល់ខ្លួននិងអ្នកដទៃក្នុងគ្រោះថ្នាក់ចរាចរណ៍នោះផងទេ។*

*សរុបមក «សីលប្រាំ» គឺជាធម៌អប់រំមួយដ៏សមរម្យបំផុតដែលបុគ្គលម្នាក់ៗគប្បីមានជាប្រចាំ ដើម្បីធ្វើឲ្យដំណើរជីវិតរស់នៅប្រចាំថ្ងៃ*

របស់ខ្លួនអាចរកឃើញនូវពន្លឺនៃសេចក្តីសុខដែលជាបំណងប្រាថ្នាដំបូងបង្អស់ក្នុងសភាពជាមនុស្ស។ ក្រៅពីនេះព្រះពុទ្ធនៅបានអប់រំមនុស្សម្នាក់ៗឲ្យមានសីលធម៌ល្អ ចេះរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមស្រឡាញ់រាប់អានគ្នា ទៅវិញទៅមកជួយយកអាសាគ្នានិងមិនបៀតបៀនគ្នា។ ប្រការសំខាន់ជាងនេះទៅទៀត គឺព្រះពុទ្ធបានអប់រំមនុស្សឲ្យជឿជាក់លើកម្លាំងនិងសមត្ថភាពផ្ទាល់ខ្លួនប្រកាន់យកនូវការព្យាយាមអត់ធ្មត់ប្រព្រឹត្តឲ្យបានខ្ជាប់ខ្ជួននូវធម៌កណ្តាលធម៌អហិង្សា ដើម្បីដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅ។

**២. ចតុរារិយសច្ចៈ (Four Noble Truths)**

នេះជាសភាវៈទ្រទ្រង់លោកមួយទៀតដែលព្រះពុទ្ធបានរកឃើញក្នុងន័យជាសេចក្តីពិតដ៏ប្រសើរខ្ពង់ខ្ពស់ទាំងបួនទាក់ទងទៅនឹងសេចក្តីទុក្ខ។

សេចក្តីសុខតែងមានគូប្រសប់របស់ខ្លួនគឺសេចក្តីទុក្ខដែលមនុស្សម្នាក់ៗតែងជួបប្រទះតិចឬច្រើនក្នុងដំណើរជីវិតរបស់ខ្លួន។ សេចក្តីទុក្ខ(Suffering)បានដល់សេចក្តីព្រួយលំបាកមិនសុខស្រួលតាមផ្លូវកាយនិងផ្លូវចិត្ត (Physical and mental Suffering)។ ក្នុងចតុរារិយសច្ចៈ ព្រះពុទ្ធបានចង្អុលបង្ហាញយើងឲ្យបានដឹងច្បាស់ពីប្រភព, ពីមូលហេតុនៃសេចក្តីទុក្ខនិងបង្ហាញពីវិធី, មាគ៌ាទាំងឡាយដែលត្រូវប្រកាន់យក ដើម្បីបញ្ចៀសសេចក្តីទុក្ខកុំឱ្យកើតមានធ្ងន់ធ្ងរខ្លាំងពេក ចំពោះជីវិតរស់នៅជាមនុស្សរបស់យើងម្នាក់ៗ។

**២.១ ទុក្ខអរិយសច្ចៈ** ជាសេចក្តីទុក្ខដែលកើតមកពីជាតិកំណើតឬការកើតរបស់មនុស្សហើយដែលត្រូវឆ្លងកាត់ជាចាំបាច់នូវតំណាក់កាលទាំងបួននៃជីវិតពោល គឺការកើត (ជាតិ) ជាទុក្ខទីមួយ បន្ទាប់មកគឺភាពចាស់ជរាទ្រុឌទ្រោមនៃរាងកាយ (ជរា) ជាទុក្ខទីពីរបន្ទាប់មកទៀតគឺទុក្ខព្រោះមានជំងឺប្រចាំកាយ (ព្យាធិ) ជាទុក្ខទីបី ហើយជាចុងក្រោយគឺទុក្ខព្រោះសេចក្តីស្លាប់ (មរណភាព) បានន័យជាសរុបខ្លីមកថា ជាតិទុក្ខ, ព្យាធិទុក្ខ, ជរាទុក្ខ និង មរណៈទុក្ខ។

**២.២- ទុក្ខសមុទយអរិយសច្ចៈ (The rising of Dukkha)** គឺជាការពន្យល់ពីហេតុនាំឲ្យមានសេចក្តីទុក្ខដែលបណ្តាលមកពីមូលហេតុពីរយ៉ាង : តណ្ហានិងអវិជ្ជា។

តណ្ហា ប្រែមកថាជាចំណង់សេចក្តីស្រេកឃ្លានឬសេចក្តីប្រាថ្នាចង់បាននូវអ្វីមួយ។ ការចង់បានដោយឥតពិចារណាបាននាំឲ្យមនុស្សហ៊ានប្រព្រឹត្តនូវអំពើមិនគួរគប្បីណាមួយដូចជាការប្រព្រឹត្តខុសក្នុងកាមអំពើឈ្នានីសអំពើកាប់សម្លាប់គ្នាជាដើម។ តណ្ហាក៏មានន័យម្យ៉ាងទៀតថា សេចក្តីប្រាថ្នាចង់ទៅកើតនៅទីកពង់សមគួរណាមួយដូចជាទៅកើតនៅឋានសួគ៌ឬឋានតុសិតជាដើម។ តណ្ហាក៏មានន័យមួយបែបទៀតថាជាសេចក្តីប្រាថ្នាចង់បានទ្រព្យសម្បត្តិយសស័ក្តិ អំណាច តេជៈ ឬឥទ្ធិពលផ្សេងៗ។ ជារួមបើសេចក្តីប្រាថ្នានេះបានសម្រេចឬមិនបានសម្រេចសេចក្តីទុក្ខនឹងកើតមានដូចគ្នា។ ចំពោះអវិជ្ជាវិញដែលជាប្រភពនៃសេចក្តីទុក្ខដែរនោះមានន័យថាជាការមិនបានដឹងច្បាស់ឬភាពល្ងិតល្ងង់ ដោយប្រការណាមួយទៅលើហេតុការណ៍អ្វីមួយដែលជាប្រភពនាំឲ្យកើតតណ្ហា បង្កបានជាជម្លោះទាស់ទែងគ្នាក្នុងគ្រួសារ, ស្ថាប័នបំពេញការងារឬធំទូលាយជាងនេះទៅទៀតគឺសង្គមជាតិ។

**២.៣- ទុក្ខនិរោធអរិយសច្ចៈ** (The cessation of Dukkha) ជាការរំលត់ទុក្ខដោយបំបាត់អវិជ្ជា និងរំលាយចោលនូវតណ្ហាកុំឲ្យកើតមានក្នុងចិត្តគំនិតរបស់បុគ្គលម្នាក់ៗ។

**២.៤- មគ្គអរិយសច្ចៈ** (the Noble path) ជាមាគ៌ាដើម្បីរំលត់ទុក្ខដោយប្រកាន់យកនូវផ្លូវមួយដែលមនុស្សទាំងឡាយអាចទទួលយកមកអនុវត្តបានគ្រប់ៗគ្នា។

**៣- អដ្ឋង្គិកមគ្គ** (the noble Eightfold path or Middle path) មានន័យថាជាផ្លូវកណ្តាលទាំងប្រាំបីដែលនាំឲ្យមនុស្សទទួលបាននូវសេចក្តីសុខ។ ផ្លូវកណ្តាលទាំងប្រាំបីនោះរួមមាន :

**៣.១- សម្មាទិដ្ឋិ** (Right understanding) មានន័យថាការស្វែងយល់ឱ្យឃើញពិត នូវសភាវធម៌ទាំងពួងហើយពេញចិត្តយល់ព្រមប្រតិបត្តិតាមផ្លូវត្រូវ ដើម្បីបំបាត់អវិជ្ជា និងរំលាយតណ្ហា។

**៣.២- សម្មាសង្កប្ប** (Right thought) មានន័យថាការត្រិះរិះពិចារណាបានត្រឹមត្រូវ ពោលគឺត្រិះរិះដោយមិនប្រមាថមើលងាយឬធ្វេសប្រហែសព្រមទាំងមិនបៀតបៀនចំពោះមនុស្សសត្វទូទៅ។

**៣.៣- សម្មាវាចា** (Right speech) បានន័យថាវាចាត្រឹមត្រូវនិយាយស្តីត្រឹមត្រូវទៀង

ត្រង់ហើយទៀងទាត់ដោយវៀរចាកនូវវាចាទុច្ចរិតបួនយ៉ាង : មុសាវាទឬសំដីភូតភរកុហកបោកបញ្ឆោត។ បិសុនាវាទឬសំដីញុះញង់បំបែកបំបាក់អ្នកដទៃ។ ផរុសវាទឬការពោលពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃ និងសម្ផប្បលាវាទឬសម្ដីរោយរាយប៉ប៉ាច់ប៉ប៉ោចឥតប្រយោជន៍។

**៣.៤- សម្មាកម្មន្ត** (Right action) ជាអំពើប្រព្រឹត្តត្រឹមត្រូវវៀរចាកអំពើក្នុងកាយទុច្ចរិតទាំងបីយ៉ាង គឺបាណាតិបាតឬអំពើសម្លាប់ជីវិតអទិន្នាទានឬអំពើលួចទ្រព្យសម្បត្តិអ្នកដែលគេមិនបានឲ្យនិងកាមេជាអំពើប្រព្រឹត្តខុសក្នុងកាមលួចលាក់សេពសន្ថវៈ ជាមួយប្រពន្ធកូនអ្នកដទៃ។

**៣.៥- សម្មាអាជីវៈ** (Right livelihood) គឺជាការចិញ្ចឹមជីវិតត្រឹមត្រូវប្រាសចាកការចិញ្ចឹមជីវិតឬប្រកបមុខរបរខុសគន្លងដូចជាមុខរបរលួចឆក់ប្លន់បោកប្រាស់ទ្រព្យសម្បត្តិអ្នកដទៃធ្វើជំនួញទុច្ចរិតដូចជាជួញដូរគ្រឿងញៀន ជួញដូរសាច់សត្វឬប្រភេទសត្វរស់ដែលច្បាប់ហាមឃាត់ជាដើម។

**៣.៦- សម្មាវាយាម** : (Right effort) ឬការព្យាយាមត្រឹមត្រូវពោលគឺព្យាយាមការពារមិនឲ្យមានអំពើអាក្រក់ឬអំពើបាបកើតមានព្យាយាមក្នុងការងារមុខរបរសុចរិតឲ្យសម្រេចប្រយោជន៍ព្យាយាមរក្សានិងកសាងនូវអំពើល្អអំពើដែលមានប្រយោជន៍ដល់សង្គមជាតិព្យាយាមដុសខាត់ចិត្តគំនិតឲ្យស្អាតល្អផូរផង់មិនធ្លាក់ចូលទៅក្នុងអបាយមុខទាំងបីស្រី, ស្រា, ល្បែង។

**៣.៧- សម្មាសតិ** (Right mindfulness) គឺការតាំងសតិត្រឹមត្រូវការនឹករលឹកឃើញនិងភ្ញាក់រលឹកដឹងខ្លួនជានិច្ចនិងការពារកុំឲ្យវិញ្ញាណទាំងប្រាំមានភ្នែកត្រចៀកអណ្ដាតច្រមុះកាយទទួលនូវអារម្មណ៍អាក្រក់បាន។

**៣.៨- សម្មាសមាធិ** (Right concentration) គឺការធ្វើសមាធិត្រឹមត្រូវ បានន័យថាតាំងចិត្តឲ្យហ្នឹងហ្នមិនរវើរវាយទៅតាមអារម្មណ៍មិនល្អដោរនាចរបស់ខ្លួន។

*សរុបមកអដ្ឋង្គិកមគ្គឬផ្លូវកណ្តាលអាចហៅបានម្យ៉ាងទៀតថា «សីលសមាធិបញ្ញា» ដែលក្នុងនោះ សីលបានដល់សម្មាវាចាសម្មាកម្មន្តៈនិងសម្មាអាជីវៈ។ សមាធិបានដល់សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ។*

*រីឯបញ្ញាវិញបានដល់សម្មាទិដ្ឋិនិងសម្មាសង្កប្បៈ។*

- សីល
  - សម្មាវាចា
  - សម្មាកម្មន្តៈ
  - សម្មាអាជីវៈ
- សមាធិ
  - សម្មាវាយាមៈ
  - សម្មាសតិ
  - សម្មាសមាធិ
- បញ្ញា
  - សមាទិដ្ឋិ
  - សម្មាសង្កប្បៈ

**៤. បដិច្ចសមុប្បាទ** (Dialectic) *នេះជាធម៌រកឃើញក្នុងពេលនៃការត្រាស់ដឹង* (Illumination) *របស់ព្រះពុទ្ធ។ គេអាចហៅធម៌នេះថាបដិច្ចសមុប្បាទឬទស្សនវិជ្ជាហេតុ-ផល* (Cause-Effect)*។ គេអាចពន្យល់ធម៌នេះតាមហេតុផលសរុបបួនយ៉ាង :*

*បើនេះមាននោះក៏មាន*
*បើនេះគ្មាននោះក៏គ្មាន*
*បើនេះកើតនោះក៏កើត*
*បើនេះរលត់នោះក៏រលត់*

*ព្រះអង្គបានពិចារណាផ្សារភ្ជាប់ទ្រឹស្តីនេះទៅនឹងហេតុផលនៃការកើតស្លាប់របស់មនុស្សក្នុងវដ្តសង្សារ ដែលមានបច្ច័យទាក់ទងគ្នាចំនួនដប់ពីរ ហើយបានបញ្ចប់ទៅវិញជាមួយនឹងការធ្វើមរណកាលដែលជាវត្ថុទៀងទាត់ចៀសមិនផុត។ គួរកត់សម្គាល់ថាការពិចារណារកឃើញពីហេតុ-ផលនៃអត្ថិភាពរបស់មនុស្សក្នុងលក្ខណៈបែបនេះមិនមែនមានន័យថាព្រះអង្គបានហាមប្រាមមិនឲ្យកើតមានជីវិតមនុស្សលោកនៅលើផែនដីនេះទេ ប៉ុន្តែព្រះអង្គគ្រាន់តែបង្ហាញឲ្យយើងបានឃើញពីហេតុផលនៃការស្លាប់បណ្តាលមកពីការកើតដែលជាហេតុបច្ច័យទាក់ទងដំបូងនាំឲ្យមានការ*

ស្លាប់។ តទៅនេះជាហេតុបច្ច័យតៗគ្នាទាំងដប់ពីរយ៉ាងនៃការកើតស្លាប់ដែលព្រះពុទ្ធបានរកឃើញដោយចាប់ផ្ដើមពីអវិជ្ជា។

**• អវិជ្ជានាំឲ្យកើតសង្ខារ**

ដូចបានលើកឡើងពីខាងលើរួចមកហើយ អវិជ្ជាបានដល់ការមិនបានដឹងច្បាស់។ ពីព្រោះតែការមិនបានដឹងច្បាស់ថាមានអ្វីៗជាបន្តទៅទៀតមុននឹងចូលទៅដល់តំណាក់កាលចុងក្រោយនៃការស្លាប់នេះហើយ បានជាមានការកើតជាជីវិតជាបន្តបន្ទាប់ដែលគេហៅថាសង្ខារនៅលើដែនដីយើងនេះ។

**• សង្ខារនាំឲ្យកើតវិញ្ញាណ**

វិញ្ញាណជាការទទួលដឹងលោកខាងក្រៅដែលបណ្ដាលមកពីការមានជីវិតសង្ខារ។

**• វិញ្ញាណនាំឲ្យកើតនាមរូប**

ដោយសារតែវិញ្ញាណទាំងប្រាំ ដែលជាគ្រឿងទទួលដឹងនូវអារម្មណ៍ខាងក្រៅទើបកើតបានជារូបរាងយ៉ាងនេះយ៉ាងនោះប្រកបដោយឈ្មោះសម្រាប់ហៅជាគ្រឿងសម្គាល់និងមានរូបរាងពិតប្រាកដ ដែលជាសរុបគេហៅថានាមរូប។

**• នាមរូបនាំឲ្យកើតអាយតនៈ**

អាយតនៈជាគ្រឿងទទួលដឹងនូវអារម្មណ៍ថាយ៉ាងនេះឬយ៉ាងនោះដែលស្ថិតនៅខាងក្នុងនៃវិញ្ញាណទាំងប្រាំ ហើយអាចឲ្យមនុស្សវិនិច្ឆ័យឬសន្និដ្ឋានបានពីហេតុការណ៍ទាំងឡាយ។

**• អាយតនៈនាំឲ្យកើតផស្សៈ**

ផស្សៈជាអារម្មណ៍មកប៉ះពាល់ត្រូវអាយតនៈដែលស្ថិតនៅខាងក្នុងនៃវិញ្ញាណនីមួយៗ។

**• ផស្សៈនាំឲ្យកើតវេទនា**[2](sensation)។ វេទនាជាការទទួលអារម្មណ៍ថាយ៉ាងនេះឬយ៉ាងនោះតួយ៉ាងដូចជាអារម្មណ៍ជាសុខឬជាទុក្ខក្ដៅក្រដាក់ជាដើម។

---

២- តាមធម៌ព្រះពុទ្ធវេទនាមានប្រាំយ៉ាង : ទុក្ខវេទនា, សុខវេទនា, ឧបេក្ខាវេទនា (មិនសុខមិនទុក្ខ), សោមនស្សវេទនា, ទោមនស្សវេទនា។

• *វេទនានាំឱ្យកើតតណ្ហា*

*ដោយសារវេទនានាំឲ្យកើតជាតណ្ហា។ តណ្ហាគឺជាផលរីឯវេទនាគឺជាហេតុ។ តណ្ហាមានន័យថាចំណង់របស់មនុស្ស។ ជាតិជាមនុស្សតែងតែមានចំណង់ចង់បាននេះឬបាននោះហើយក៏អាចជាចំណង់ជាកាមតណ្ហាផ្សារភ្ជាប់ទៅនឹងរូប សំឡេងក្លិន រស និងសម្ផស្ស។*

• *តណ្ហានាំឱ្យកើតឧបាទាន*

*ដោយសារតណ្ហានាំឱ្យកើតបានជាការជាប់ជំពាក់ទៅលើអ្វីមួយកាលពីពេលនៅរស់។*

• *ឧបាទាននាំឲ្យកើតភព*

*ដោយសារការជាប់ជំពាក់ទៅលើអ្វីមួយកាលពីពេលនៅរស់នោះហើយបានជានាំទៅដល់ការស្វះស្វែងរកភពដែលជាទីយោនយកកំណើតរបស់រូបកាយ។*

• *ភពនាំឱ្យកើតជាតិ*

*ជាតិបានដល់ការយោនយកកំណើត, ជាការចាប់យកជាតិកំណើតរបស់មនុស្សម្នាក់ៗ។*

• *ជាតិនាំឱ្យកើតជរា*

*ដោយសារតែការកើតបាននាំឲ្យមានហេតុផលមួយទៀតគឺការវិវត្តន៍* (evolution) *ពីវ័យក្មេងរហូតដល់ វ័យចាស់ដែលគេហៅថាជរានោះឯង។*

• *ជរានាំឱ្យកើតមរណៈ*

*ជរាមានន័យថាភាពទ្រុឌទ្រោមខាងរូបកាយនិងកម្លាំងកាយ ដោយសារតែជរាភាពនេះបាននាំឲ្យមនុស្សមានជំងឺ (ព្យាធិ) មកបៀតបៀនរាងកាយហើយអាចនាំទៅដល់សេចក្តីស្លាប់ដែលជាប្រការមិនអាចចៀសផុតបាន។ ប្រការនេះហើយដែលគេហៅថាជរានាំឲ្យកើតមរណៈ។ ដូច្នេះតាមរយៈបដិច្ចសមុប្បាទរបស់ព្រះពុទ្ធគេអាចយល់បានថាបើភាវៈណាមួយកើតឡើងភាវៈដទៃទៀតក៏កើតឡើងបន្តបន្ទាប់គ្នា។ ផ្ទុយទៅវិញបើភាវៈណាមួយរលត់ភាវៈឯទៀតក៏រលត់តៗគ្នាទៅយ៉ាងនោះដែរ។*

## សេចក្តីសន្និដ្ឋាន

*ទាំងអស់នេះ គឺជាទស្សនវិជ្ជាសីលធម៌ទាំងបួន ដែលព្រះពុទ្ធបានត្រិះរិះពិចារណារកឃើញក្នុងពេលដែលព្រះអង្គបានត្រាស់ដឹងជា*

ព្រះពុទ្ធ។ ទស្សនវិជ្ជាសីលធម៌ទាំងនេះមានសារៈសំខាន់បំផុតចំពោះអត្ថិភាពជាមនុស្ស ដើម្បីឈានទៅកសាងនូវទំនាក់ទំនងសង្គមមួយប្រកបដោយភាពសុខដុមរមនាគ្មានអំពើហិង្សា និងការរើសអើង។

# គន្ថនិទ្ទេស


- សោម ង៉ន ពន្លឺពុទ្ធសាសនា បោះពុម្ពលើកទី៣ រោងពុម្ពភ្នំពេញ ឆ្នាំ២០០៥។
- អ៊ុំ ប៉ុម ប្រវត្តិគំនិតនយោបាយបស្ចិមប្រទេសគ្រិះស្ថានបោះពុម្ពផ្សាយអង្គរ ឆ្នាំ២០០៨។